

# អេង៉ សុត

(១៩២២-១៩៧៥ ?)

Eng Soth

*ប្រមូលផ្តុំឯកសារដោយ*

*បណ្ឌិតសភាចារ្យ ឃីងហុកឌី*

អេង៉សុត *កើតរវាងឆ្នាំ១៩២២*[1] *ហើយបានបាត់ខ្លួនរវាងឆ្នាំ១៩៧៥។*

[1] *នៅឆ្នាំ១៩៧២កាលលោកជាប់ឆ្នោតជាតំណាងរាស្ត្រក្នុងជន្មាយុ៥១ឆ្នាំ។ ឯលោកប៊ុនចន្ទមុលជាប់ឆ្នោតជាតំណាងរាស្ត្រជំនាន់លោកក្នុងជន្មាយុ៥៨ឆ្នាំ ហើយលោកកើតនៅឆ្នាំ១៩១៦គឺលោកអេងសុតប្អូនលោកប៊ុនចន្ទមុល៧ឆ្នាំ។ លោកតាន់គីមហួនជាតំណាងរាស្ត្រជំនាន់គ្នានៅឆ្នាំ១៩៧២អាយុ៤៨ឆ្នាំ។ តាមការគិតលេខគឺលោកអេងសុតមានកំណើតរវាងឆ្នាំ១៩២២។ តែយើងមិនបានដឹងទីកន្លែងកំណើតលោកទេ។*

*ជាប់ឆ្នោតជាតំណាងរាស្ត្រ នៅក្នុងមណ្ឌលភ្នំពេញក្នុងសម័យសាធារណរដ្ឋខ្មែរនាឆ្នាំ១៩៧២។ នាពេលនេះលោកមានជន្មាយុ ៥១ឆ្នាំ។*

*លោកជាឧត្តមមន្ត្រីចៅក្រមក្នុងក្រសួងយុត្តិធម៌ភ្នំពេញ។លោកជាសមាជិកពុទ្ធិកសមាគមដែលមានសម្តេចសង្ឃហួតតាតជាប្រធានហើយលោកបានជាប់ឆ្នោតជាអនុប្រធានសមាគមនេះ។*

*លោកជាសមាជិកគណកម្មការវប្បធម៌និងប្រវត្តិសាស្ត្រខ្មែរ។ លោកអេងសុតបានបន្សល់ស្នាដៃមួយចំនួនដែលរក្សាទុករហូតដល់សព្វថ្ងៃ។ ស្នាដៃសំខាន់គឺ កម្រង* **ឯកសារមហាបុរសខ្មែរ** *ដែលអ្នកសិក្សាស្រាវជ្រាវយកមកបោះផ្សាយឡើងវិញ ជាច្រើនលើកច្រើនគ្រាមកហើយចាប់ពីទសវត្សរ១៩៨០មក។ ក្រសួងអប់រំក៏បានយកមកបោះផ្សាយឡើងវិញដែរ។ល។*

*នេះស្នាដៃលោកអេងសុត ដែលស្រង់បញ្ចីទស្សនាវដ្តី« ពន្លឺពុទ្ធិចក្រ» ដូចមានខាងក្រោមនេះ៖*

– ទស្សនាវដ្ដីពន្លឺពុទ្ធចក្រ, លេខ២១, ពុទ្ធិកសមាគម-មជ្ឈមណ្ឌលកម្ពុជរដ្ឋ, ខែមករា ឆ្នាំ១៩៦៦
– ទស្សនាវដ្ដីពន្លឺពុទ្ធចក្រ, លេខ២២, ពុទ្ធិកសមាគម-មជ្ឈមណ្ឌលកម្ពុជរដ្ឋ, ខែមេសា ឆ្នាំ១៩៦៦
– ទស្សនាវដ្ដីពន្លឺពុទ្ធចក្រ, លេខ២៣, ពុទ្ធិកសមាគម-មជ្ឈមណ្ឌលកម្ពុជរដ្ឋ, ខែកក្កដា ឆ្នាំ១៩៦៦
– ទស្សនាវដ្ដីពន្លឺពុទ្ធចក្រ, លេខ២៤, ពុទ្ធិកសមាគម-មជ្ឈមណ្ឌលកម្ពុជរដ្ឋ, ខែតុលា ឆ្នាំ១៩៦៦
– ទស្សនាវដ្ដីពន្លឺពុទ្ធចក្រ, លេខ២៥, ពុទ្ធិកសមាគម-មជ្ឈមណ្ឌលកម្ពុជរដ្ឋ, ខែមករា ឆ្នាំ១៩៦៧
– ទស្សនាវដ្ដីពន្លឺពុទ្ធចក្រ, លេខ២៦, ពុទ្ធិកសមាគម-មជ្ឈមណ្ឌលកម្ពុជរដ្ឋ, ខែមេសា ឆ្នាំ១៩៦៧
– ទស្សនាវដ្ដីពន្លឺពុទ្ធចក្រ, លេខ២៧, ពុទ្ធិកសមាគម-មជ្ឈមណ្ឌលកម្ពុជរដ្ឋ, ខែកក្កដា ឆ្នាំ១៩៦៧
– ទស្សនាវដ្ដីពន្លឺពុទ្ធចក្រ, លេខ២៨, ពុទ្ធិកសមាគម-មជ្ឈមណ្ឌលកម្ពុជរដ្ឋ, ខែតុលា ឆ្នាំ១៩៦៧
– ទស្សនាវដ្ដីពន្លឺពុទ្ធចក្រ, លេខ២៩, ពុទ្ធិកសមាគម-មជ្ឈមណ្ឌលកម្ពុជរដ្ឋ, ខែមករា ឆ្នាំ១៩៦៨
– ទស្សនាវដ្ដីពន្លឺពុទ្ធចក្រ, លេខ៣០, ពុទ្ធិកសមាគម-មជ្ឈមណ្ឌលកម្ពុជរដ្ឋ, ខែមេសា ឆ្នាំ១៩៦៨
– ទស្សនាវដ្ដីពន្លឺពុទ្ធចក្រ, លេខ៣១, ពុទ្ធិកសមាគម-មជ្ឈមណ្ឌលកម្ពុជរដ្ឋ, ខែកក្កដា ឆ្នាំ១៩៦៨
– ទស្សនាវដ្ដីពន្លឺពុទ្ធចក្រ, លេខ៣២, ពុទ្ធិកសមាគម-មជ្ឈមណ្ឌលកម្ពុជរដ្ឋ, ខែតុលា ឆ្នាំ១៩៦៨
– ទស្សនាវដ្ដីពន្លឺពុទ្ធចក្រ, លេខ៣៣, ពុទ្ធិកសមាគម-មជ្ឈមណ្ឌលកម្ពុជរដ្ឋ, ខែមករា ឆ្នាំ១៩៦៩
– ទស្សនាវដ្ដីពន្លឺពុទ្ធចក្រ, លេខ៣៤, ពុទ្ធិកសមាគម-មជ្ឈមណ្ឌលកម្ពុជរដ្ឋ, ខែមេសា ឆ្នាំ១៩៦៩
– ទស្សនាវដ្ដីពន្លឺពុទ្ធចក្រ, លេខ៣៥, ពុទ្ធិកសមាគម-មជ្ឈមណ្ឌលកម្ពុជរដ្ឋ, ខែកក្កដា ឆ្នាំ១៩៦៩
– ទស្សនាវដ្ដីពន្លឺពុទ្ធចក្រ, លេខ៣៦, ពុទ្ធិកសមាគម-មជ្ឈមណ្ឌលកម្ពុជរដ្ឋ, ខែតុលា ឆ្នាំ១៩៦៩
– អេង សុត, ការសិក្សាច្បាប់គ្រប់មាត្រាទាំងអស់ក្នុងក្រមព្រហ្មទណ្ឌ, ផ្សាយលើកទី២, ១៩៦៤
– អេង សុត, ឯកសារមហាបុរសខ្មែរ, ភាគ១-៧, ១៩៦៩
– អេង សុត, ឯកសារមហាបុរសខ្មែរ, ភាគ១, លេខ១ដល់១២, ១៩៦៩
– អេង សុត, ឯកសារមហាបុរសខ្មែរ, ភាគ២, លេខ១៣ដល់២២, ១៩៦៩
– អេង សុត, ឯកសារមហាបុរសខ្មែរ, ភាគ៣, លេខ២៣ដល់៣៣, ១៩៦៩

- អេង សុត, ឯកសារមហាបុរសខ្មែរ, ភាគ៤, លេខ៣៤ដល់៤៤, ១៩៦៩
- អេង សុត, ឯកសារមហាបុរសខ្មែរ, ភាគ៥, លេខ៤៥ដល់៥៥, ១៩៦៩
- អេង សុត, ឯកសារមហាបុរសខ្មែរ, ភាគ៦, លេខ៥៦ដល់៦៦, ១៩៦៩
- អេង សុត, ឯកសារមហាបុរសខ្មែរ, ភាគ៧, លេខ៦៧ដល់៧៦, ១៩៦៩
- អេង សុត, ការស្រាវជ្រាវព្រះពុទ្ធសាសនាផ្នែកហីនយាន, លេខ២៧, ១៩៦៧, ទំព័រ១៣ ១៨
- អេង សុត, បទល្មើសប្រឆាំងនឹងសាសនារបស់ផ្ទើ, លេខ២៧, ១៩៦៧, ទំព័រ២៤ ២៧
- អេង សុត, ជីវប្រវត្តិនៃសម្តេចព្រះសុគន្ធមានបុណ្យ, លេខ២៩, ១៩៦៨, ទំព័រ៦២ ៦៧
- អេង សុត, ជីវប្រវត្តិនៃសម្តេចព្រះសុគន្ធាធិបតី ( ប៉ិម ), លេខ៣០, ១៩៦៨, ទំព័រ២២ ២៣

ឧបសម្ពន្ធ



សភាជាតិនីតិកាលទី១នៃសាធារណរដ្ឋខ្មែរ ឆ្នាំ១៩៧២

ខាងក្រោមនេះគឺតំណាងរាស្ត្រ សាធារណរដ្ឋខ្មែរនៅមណ្ឌលភ្នំពេញ៖


1— PHNOM-PENH
— Cir. Chamrœun Reath
1— M. OS SLAIMAN
âge : 34 ans
Professeur premier cycle
2— M. THACH CHAN
âge : 50 ans
Contrôleur des Eaux et Forêts
— Cir. Chom Chau
3— M. MEN HOEUN
âge : 28 ans
Ingénieur
4— M. CHUONG ENG HAP
âge : 32 ans
Diplômé de l'Ecole Supérieure de Commerce
— Cir. Daun Penh
5— M. THACH TOAN
âge : 37 ans
Professeur agrégé en Médecine
6— M. BUN CHAN MOL
âge: 58 ans
Off. Supérieur des FANK
7— M. KEUK KY LIM
âge: 35 ans
Docteur en Pharmacie
— Cir. Serei Reath
8— M. TAN KIM HUON
âge: 48 ans
Ingénieur agronome
9— M. ENG SOTH
âge: 51 ans
Odam Chaukram
10— Mme. SIM VANSY
âge: 52 ans
Assistante sociale
2— KANDAL
— Cir. Takhmau
11— M. CHAU HUOT NALY
âge: 37 ans
Brevet de Fonctionnaire Moyen de l'ENA
12— M. TAN KIM CHHOU
âge: 30 ans
Licencié en droit
Magist. Conseiller Sala Outor
— Cir. Chbar Ampeou
13— M. UNG BUN HOR
âge: 42 ans
Ex. Ambassadeur à Cuba
Directeur de recette de finance
14— M. HUOT NIL
âge : 40 ans
Infirmier Dispensaire Takhmau

នេះជារូបតំណាងរាស្ត្រសម័យសាធារណរដ្ឋខ្មែរអាណត្តិទី១មានទាំងអស់១២៦នាក់ៗ

(សូមអានទស្សនាវដ្តី ***Cambodge nouveau,*** troisième année n°19, mai septembre 1972, p.35-39 : « Les députés de la première législature de la République khmère »)សូមអានបន្ថែមនិក្ខេបបទបណ្ឌិត បណ្ឌិតសភាចារ្យ រស់ចន្ត្រាបុត្រ : ROS Chantrabot, *La République khmère,* Ed. L'Harmattan, 1993, 216 p.



ឯកសារ

# មហាបុរសខ្មែរ

ព្រះរាជពង្សាវតារខ្មែរ តាមសាស្ត្រាស្លឹករិត ពិតឥតក្លែងក្លាយ

ផ្សាយចេញរាល់ថ្ងៃ តម្លៃ ៣ រៀល

អ្នកស្រាវជ្រាវ
អេង-សុត
សមាជិកនៃគណកម្មការ
ប្រវត្តិសាស្ត្រ
និងវប្បធម៌

លេខ ១

រក្សាសិទ្ធិ
គ្រប់យ៉ាង

ពញាជ័យ ស្តេចយាងទៅសោយរាជ្យ (គំនូរនេះគូរពី គ.ស. ១៨៣៩)

ផែនដី (១) ព្រះបាទអង្គជ័យ ឬ ព្រះបាទត្រសក់ផ្អែម

ពី គ.ស. ៩៩៨ ដល់ គ.ស ១០៤៩

ព.ស. ១៥៤២ គ.ស. ៩៩៨ មហាសករាជ ៩៣០ ចុល្លសករាជ ៣៦០ ឆ្នាំខាល សំរឹទ្ធិស័ក

ពញាជ័យ ព្រះជន្ម ៥០ ឆ្នាំ (បើជា ៥៣ ឆ្នាំទើបត្រូវ នឹង រឿងខាងក្រោម)

(១) សម្តេចព្រះសង្ឃរាជ ជួន-ណាត ទ្រង់សព្វព្រះរាជហឫទ័យ ឲ្យប្រើពាក្យ "រជ្ជកាល" ជំនួសពាក្យ "ផែនដី" នេះវិញ ប៉ុន្តែការកែប្រែនេះ នឹងនាំឲ្យមានពាក្យថ្មីឃ្លាតឆ្ងាយពីច្បាប់ដើម ។ ដូច្នេះដើម្បីកុំឲ្យខុសពីច្បាប់ដើម យើងសូមរក្សាទុកពាក្យ "ផែនដី" នេះឲ្យគង់នៅដដែល ។



ឯកសារ

# មហាបុរសខ្មែរ

ព្រះរាជពង្សាវតារខ្មែរ តាមសាស្ត្រាស្លឹករិត ពិតឥតក្លែងក្លាយ

ផ្សាយចេញរាល់ថ្ងៃ តម្លៃ ៣ រៀល

អ្នកស្រាវជ្រាវ
អេង-សុត
លេខ ៧៥
រក្សាសិទ្ធិ
គ្រប់យ៉ាង

ស្ពាននាគ ដែលឋិតនៅត្រង់ចុងខាងជើង នៃមហាវិថីព្រះបាទនរោត្តម

ផែនដី ព្រះបាទនរោត្តម (ត)

ព.ស. ២៤០៤ គ.ស. ១៨៦០ ម.ស. ១៧៨២ ច.ស. ១២២២

ថ្ងៃសុក្រ ១៣ កើត ខែពិសាខ ឆ្នាំរកាឧត្តមស័ក គ.ស ១៨៩៧ ។ មានសៀមឈ្មោះគូស ម...

ឈរជាប្រេស៊ីដង់សុបេរីយ៉េ នៅក្រុងភ្នំពេញ ជួយទំនុកបំរុងរាជការថ្វាយ ជាជំនួសមានសៀម...




ឯកសារមហាបុរសខ្មែរ បោះពុម្ពដំបូងជាវគ្គៗចេញផ្សាយរៀងរាល់ថ្ងៃដូចជាកាសែតដែលរាជរដ្ឋាភិបាលបានបិទលែងឲ្យបន្តដំណើរនាឆ្នាំ១៩៦៩ដោយមានបញ្ហានយោបាយមានទាំងអស់៧៥លេខគឺចាប់ពីលេខ១ដល់លេខ៧៥ ហើយក្រោយមកបានចងកម្រងជា២ភាគមាន ទាំងអស់១២១៦ទំព័រខ្នាតធំ។លេខនិមួយៗមានចំនួនទំព័រប្រហែល១៥ទៅ១៦ទំព័រ។

ឯកសារមហាបុរសខ្មែរបានបោះពុម្ពវិញជាច្រើនលើកគឺចាប់ពីពេលដែលកម្ពុជាបានសន្តិភាពៈ



# ឧបសម្ពន្ធរូបភាព




៨

*អនុប្រធានពុទ្ធិកសមាគម*

លោកបានបោះពុម្ពផ្សាយអត្ថបទ អក្សរសិល្ប៍ទំនៀម «ខ្យងសង្ខ» នៅបណ្ណាគារគីមគី ឆ្នាំ១៩៦០មាន២ភាគ, ៤២៧ទំព័រ។ ការបោះពុម្ពនេះនៅបណ្ណាគារគីមគី ដោយសហការជាមួយ នាងហ៊ូ ជា អតីតសាស្ត្រាចារ្យដែលមានសញ្ញាប័ត្រសាលាបាលីជាន់ខ្ពស់ ជួយពិនិត្យកែតម្រូវតាមអក្ខរាវិរុទ្ធ។



# នេះទំព័រទី១បន្ទាប់ពីក្របក្រៅ



រឿង

សាស្ត្រាស័ខ្ទសិល្ប ជ័យ

ទី១

បម្លងពីសាស្ត្រាស្លឹករឹត

កម្មវិធីសិក្សាថ្នាក់ទី ៥ ទំនើបជាតិ

អនុវិទ្យាល័យ – វិទ្យាល័យ

អេង-សុត ទីន ឈាង.ហ៊ា

អតីតសាស្ត្រាចារ្យ – សញ្ញាប័ត្រសាលាបាឡីជាន់ខ្ពស់

ពិនិត្យកែតម្រូវតាមអក្ខរាវិរុទ្ធ

បោះពុម្ពលើកទី ១

ផ្សាយចេញពី

រោងពុម្ព ខេម-ភី បណ្ណាគារ
លេខ៤៤ វិថីគោះជំហើង.ភ្នំពេញ

ព.ស. ២៥០៣ គ.ស. ១៩៦០

រឿងទុំទាវគ្មាននាមអ្នកនិពន្ធ

តែអ្នកស្រាវជ្រាវមួយចំនួន មាន

អេងសុត, សមថាំង, ហង់ធុនហាក់, និង នាងហ៊ួ (ជាអ្នកពិនិត្យផ្ទៀងផ្ទាត់និងកែសម្រួល) បានសរសេរបុព្វបទលើសៀវភៅនេះដោយអះអាងថាជាស្នាដៃនិពន្ធដោយសន្ធរម៉ុក, ភ្នំពេញ,១៩៦០ (អត្ថបទនេះមិនចប់ហើយយកអត្ថបទភិក្ខុសោមមកបញ្ចប់)។[2]




[2] សូមអានបន្ថែមនិក្ខេបបទបណ្ឌិត ថោងផាន THONG Phan, *Etude sur Dum Dàv, roman populaire khmère*, thèse de doctorat de 3ème cycle (inédite), Paris, Université de Paris III, 1976.

# ស្នាដៃសំខាន់លោកអេងសុត

# គឺ

# ឯកសារមហាបុរសខ្មែរ

*សៀវភៅឯកសារមហាបុរសខ្មែរនេះ គឺជាកម្រងព្រះរាជពង្សាវតារកម្ពុជាដែលលោកអេងសុតប្រមូលយកមកចងក្រងជាសៀវភៅទុកជាឯកសារប្រវត្តិសាស្ត្រប្រទេសកម្ពុជា ដូចមានសេចក្តីបញ្ជាក់ក្នុងទំព័រក្រោយកម្រង សៀវភៅលោកស្រាប់ដែលមានរូបថតបង្ហាញខាងក្រោមនេះ៖*



ព្រះមេរុ ព្រះករុណាព្រះបាទនរោត្តមកំពុងសង់

## ប្រភព នៃ ឯកសារ មហាបុរសខ្មែរ

ដោយហេតុថាមាន ទ្រង់និងលោក អ្នកអាន ជា ច្រើនអង្គ, ច្រើននាក់ចង់ជ្រាប នូវប្រភពនៃសៀវភៅ ឯកសារ មហាបុរសខ្មែរនេះ ដើម្បីទុកជាកស្តុតាង សម្រាប់ជឿហើយ ទៀតតារសុំ ឲ្យទូលព្រះបង្គំ, ខ្ញុំបាទ សរសេរប្រភពនៃសៀវភៅនេះ ថ្វាយជូនឲ្យទ្រង់ជ្រាប បានជ្រាបផង ទើបទូលព្រះបង្គំ ខ្ញុំបាទ កំនាំរឿងនេះមកចុះ ក្នុងទីនេះ ដើម្បីបំពេញព្រះទ័យ, ចិត្ត ទ្រង់លោកអ្នកអានតាមបំណង ។

សូមទ្រង់ព្រះមេត្តាប្រោស, សូមជ្រាបថា :

សៀវភៅឯកសារ មហាបុរសខ្មែរ នេះជាព្រះរាជពង្សាវតារសង្ខេប ដែលបុព្វបុរសខ្មែរយើង លោកបានសរសេរទុកក្នុងក្រាំងក៏មានខ្លះ ក្នុងសៀវភៅក៏មានខ្លះ ចារលើស្លឹករឹតក៏មានខ្លះ ដើម្បីទុកជាកេរ្តិ៍ ឲ្យបច្ឆាជនដែលកើតខាងក្រោយ បានដឹងជាតិកំណើត នៃប្រទេសរបស់ខ្លួន ឲ្យបានជាក់ច្បាស់ផង ។ ប៉ុន្តែទោះបីបុព្វការី បុគ្គលទាំងនោះ មានឧត្តមគតិ ដ៏ល្អយ៉ាងនេះ

ក៏ដោយ ក៏នៅតែបន្តផងយើងសព្វថ្ងៃនេះ មិនបានជួបប្រទះនឹងក្រាំងសាស្ត្រាទាំងនោះសោះ ។ ការណ៍នេះបណ្ដាលមកពីហេតុត្ថិ ។ តាមយោបល់របស់ទូលបង្គំខ្ញុំបាទ យល់ថាការណ៍នេះ បណ្ដាលមកពីអក្ខរាវិរុទ្ធ នៃសាស្ត្រាទាំងនោះ ខុសផ្លែកពីអក្ខរាវិរុទ្ធសម័យ ឥឡូវនេះ ឆ្ងាយបន្តិច ដែលជាហេតុនាំឲ្យអ្នកអានពិបាកអានម៉្យាង បណ្ដាលមកពីការផ្សាយសម័យនោះ គ្មានមធ្យោបាយធ្វើឲ្យបានច្រើនដូចបច្ចុប្បន្ននេះផង, បណ្ដាលមកពីជនជាតិបរទេស ផ្សាយប្រវត្តិវិជ្ជានៃប្រទេសយើងជាសន្លឹកៗ ដោយវិធីបោះពុម្ព មានចំនួនច្រើនផង ម្ល៉ោះហើយ សាស្ត្រា, ក្បួនខ្នាតរបស់យើង ក៏លិចបាត់ទៅៗ ដកបង្ហល់បាត់ឈ្មោះបោះសម្ងំ យ៉ាងនេះឯង ។

ប៉ុន្តែដោយហេតុថាទូលបង្គំ ខ្ញុំបាទ, ធ្លាប់បានឮ ព្រឹទ្ធាចារ្យខ្មែរយើងតែងដំណាល ពីព្រះរាជពង្សាវតារនោះ ត្រង់នេះខ្លះ ត្រង់នោះខ្លះ ផ្លែកពីសៀវភៅបរទេស ដែលទូលបង្គំ ខ្ញុំបាទ ធ្លាប់រៀនធ្លាប់អានមកផងហើយ សាច់រឿងទៀតក៏ពីរោះ គួរឲ្យ ចង់ចេះចង់ដឹងផង ទើបទូលព្រះបង្គំ, ខ្ញុំបាទ ក៏ខំស្វះស្វែងរកក្បួនច្បាប់ទាំងនោះ ដោយវត្តអារាមខ្លះ ដោយផ្ទះសម្បែងលោកអ្នកខ្លះជាច្រើនកន្លែង ក្នុងព្រះរាជាណាចក្រ ដើម្បីបំពេញចំណង់របស់ខ្លួនតែប៉ុណ្ណោះ ។

ក្រោយមកទូលព្រះបង្គំ ខ្ញុំបាទ ក៏តេបានសាស្ត្រា, សៀវភៅ និងក្រាំងដែលស្តី ពីព្រះរាជពង្សាវតារនោះជាច្រើនគ្រាប់ ច្រើនក្បាលជាអាទិ៍ សាស្ត្រាវត្តកំពង់ត្រឡាច ក្នុងស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង១ សាស្ត្រាវត្តស័ង្ឃក្នុងស្រុកស្អាង (កណ្ដាល)១ សាស្ត្រាវត្តទ្រៀល ក្នុងស្រុកបា-រាយ ខេត្តកំពង់ធំ១ សាស្ត្រាវត្តគោកកាក ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ១ សាស្ត្រាដែលមានតម្កល់ទុក នៅក្នុងព្រះរាជបណ្ណាល័យ នាក្រុងភ្នំពេញនេះ១ សៀវភៅរបស់លោកតាខុប លោកយាយពិន ដែលជាបិតាមាតាលោកខុប-ស៊ុំខុម១ ។ ប៉ុន្តែបណ្ដាសាស្ត្រាទាំងអស់នោះ សាស្ត្រាខ្លះក៏មានតែខាងចុង បាត់ដើម សាស្ត្រាខ្លះ ក៏មាន តែខាងដើមបាត់ខាងចុង សាស្ត្រាខ្លះទៀត ក៏មានតែត្រង់នេះ ខ្លះត្រង់នោះមិនបានរៀបយ៉ាងនេះ ហើយសាស្ត្រានោះ ក៏មានសេចក្តីខុសគ្នាខ្លះផង ។ លុះប្រមូលបានយ៉ាងនេះហើយ ទូលព្រះបង្គំ ខ្ញុំបាទ ក៏មានគំនិតមួយ ចង់ផ្សាយសៀវភៅនេះ ឲ្យជនរួមជាតិខ្ញុំ បានស្គាល់ផង ហើយក៏បង្រួម បញ្ចូលគ្នា ធ្វើជាសៀវភៅតែមួយ បម្រុងនឹងដាក់ឈ្មោះថា ព្រះរាជពង្សាវតារខ្មែរ ឡើង

...ឈ្មោះរបស់សាស្ត្រាការច្រើន ដែលបានដកស្រង់មក ។ ប៉ុន្តែដោយមានមិត្តជាច្រើន ... មានលោក ម៉ៅ សារេត ជាអ្នកសប្បុរសជន «ឌីម ង់ ជាដើម បានឲ្យយោបល់ថា ឈ្មោះសៀវភៅ ដែលខ្ញុំព្រះបង្គំ ខ្ញុំបាទ បានដាក់នេះ មុខជាមិនបានជោគជ័យ ក្នុងការផ្សាយ ... ពិតព្រោះសៀវភៅដែលមានឈ្មោះថា ពង្សាវតារក្ដី ជាប្រវត្តិសាស្ត្រក្ដី ជាប្រវត្តិ...ក្ដី មានចំនួនច្រើនណាស់ទៅហើយ ដូច្នេះហើយអ្នកអានប្រាកដជាមិនអាន សៀវភៅនេះ ... ព្រោះនឹកស្មានថាសៀវភៅនេះ ក៏ដូចជាសៀវភៅនានា ដែរ ។

យោបល់របស់មិត្តទាំងនេះ បានតម្រិះស្មារតី ខ្ញុំព្រះបង្គំខ្ញុំបាទ ឲ្យនឹកឃើញថាត្រូវតែ...ខ្ញុំព្រះបង្គំខ្ញុំបាទនេះគិតឈ្មោះមួយទៀត ឲ្យផ្លែកពីគេផង ហើយឲ្យត្រូវតាមសាច់រឿងដែលមានទំនាយពីព្រះមហាក្សត្រិយ៍ផង, ពីនាម៉ឺនសព្វមុខមន្ត្រីទាំងពួក សេនាទាហានដែលមានចំណាប់...ណាន ក្នុងនៃនគរផង នឹងតាមដំណើរ ដែលបានចម្លងចេញពីឯកសារ ផ្សេងៗ ផង ។ លុះ...គិតរាល់ពេលជាយូរមក ខ្ញុំព្រះបង្គំខ្ញុំបាទ ក៏សម្រេចឲ្យឈ្មោះសៀវភៅនេះថា « ឯកសារមហាបុរសខ្មែរ » ។

« ឯកសារ មហាបុរសខ្មែរ » នេះ ខ្ញុំព្រះបង្គំខ្ញុំបាទ បានចែកចេញជាបីសម័យគឺ :

១ - សម័យមុនអង្គរ និង ក្នុងសម័យអង្គរ ,

២ - សម័យក្រោយអង្គរ ,

៣ សម័យបច្ចុប្បន្ន ។

ចំពោះសម័យទីមួយនោះ ខ្ញុំព្រះបង្គំ ខ្ញុំបាទ មិនបានបោះផ្សាយទេ ព្រោះរឿងក្នុងសម័យនោះច្រើនតែជាប់ទាក់ទងដោយរឿងព្រេង ។ សម័យទី ៣ ក៏ខ្ញុំព្រះបង្គំ ខ្ញុំបាទ មិនផ្សាយដែរព្រោះជាសម័យដែលអ្នកផង ដឹងច្បាស់ៗ នាពេលនេះហើយ ។ ឯ សម័យទី ២ ដែលបានផ្សាយ មកហើយនេះមាន...ហើយផ្លែកផង ដែលគឺមានជាប់រឿងព្រេងរបស់ព្រះបាទត្រសក់ផ្អែមខ្លះដែរ ប៉ុន្តែបើនឹកគាត...ខ្ញុំព្រះបង្គំខ្ញុំបាទ ក៏ប្រាកដថាអ្នកអានមិនយល់ ទើបបានជាដាក់ជូនមកបន្តិចនេះ ។

...នៅនេះ ...នៃសាស្ត្រាផ្សេងៗ ដូចនៅនេះ ។

អារម្ភកថា សាស្ត្រា បត្ត កំពង់ត្រឡាច

ព្រះពុទ្ធសករាជ ២៤៤៣ គ្រិស្តសករាជ ១៩០១ មហាសករាជ ១៨២៣, ចុល្លសករាជ ១២៦៣ ថ្ងៃពុធ ១១ កើត ខែមាឃ ឆ្នាំជូតទោស័ក ត្រូវនឹងថ្ងៃ ៣០ ខែ មករា ឆ្នាំ ១៩០១ លោកសម្តេចអគ្គមហាសេនាធិបតី សេរីអគ្គរក្ស សមុហៈនាយក ឪឡាឡេស៊ីយ៉ុងដូណើរដើមឈ្មោះ អ៊ុំ អាយុ ៨០ ឆ្នាំ ក្នុងផែនដី ព្រះបាទសម្តេច ព្រះនរោត្តមបរមរាមទេវាវតារ ក្នុងថ្ងៃនោះលោកសម្តេចផុះផុលអំពីជួងហាចុង៉យ មានមធុរវាចា ប្រាជ្ញនឹងប្រគ្រាក្រមការ នៅទំហោនាំង ជា យើងបានប្រតិបត្តតាមព្រះពុទ្ធសាសនា ប្រព្រឹត្តតាម ព្រះពុទ្ធានុញ្ញាតិនោះ បានធ្វើបុណ្យសាងកុសល គឺព្រះវិហារសីមាស្ពាន, និងអង្គព្រះកឋិន និងសាងស្ពានផ្លូវ បង្គន់ សាលា កុដិ និង សាងព្រះគម្ពីរក៏ច្រើនគម្ពីរហើយ នៅឡើយតែព្រះរាជពង្សាវតារ ឲ្យយ៉ាងល្អិតល្អ ។ ឥឡូវនេះយើងនឹងសាងព្រះរាជពង្សាវតារ បញ្ចូលតាំងរបៀងក្សត្រ ព្រះរាជក្សត្រ និងពង្សាវតារ មន្ត្រីរាជការ សេនាព-ហានដែលបានធ្វើចំណាច់ចំណាន ក្នុងផែនដីឲ្យបានជាពិស្តារខ្លះ ដើម្បីនឹងទុកឲ្យពូជតារចៅសន្តានដឹងស្គាល់ឲ្យជាក់ប្រាកដតទៅ ។

# អារម្ភកថា សាស្ត្រារបស់ព្រះរាជបណ្ណាល័យ

## ក្រុងកម្ពុជាធិបតី

ក្រុងភ្នំពេញ នៅថ្ងៃចន្ទ ៦ កើត ខែចេត្រ ឆ្នាំម្សាញ់ឯកស័ក ព្រះពុទ្ធសករាជ ២៤៧២ ត្រូវនឹងថ្ងៃ ១៥ ខែ មេសា ឆ្នាំ ១៩២៩ ។ ព្រះរាជនិពន្ធ

ព្រះករុណាព្រះបាទសម្តេច ព្រះស៊ីសុវត្ថិមុនីវង្ស ចមចក្រពង្ស ហរិរាជបរមិន្ទរភូវណៃ ក្រៃកែវហ្វា សុខ្លាខៃ្ល ព្រះចៅក្រុងកម្ពុជាធិបតី ជាអម្ចាស់ជីវិតលើត្បូង ។ ទ្រង់ព្រះរាជតម្រិះអំពីព្រះរាជពង្សាវតារ ក្រុងកម្ពុជាធិបតីជា មានតែសរសេរដៃជាអក្សរខ្មែរ នៅក្នុងក្រុមព្រះរាជនិពន្ធ នៃព្រះបរមរាជវាំង តែសេចក្តីនោះទ្រង់បានទតឡើងវិញ ឃើញមានតាំងពីព្រះពុទ្ធ-

សករាជ ១៤៤ មុនគ្រិស្តសករាជ ៤០០ ឆ្នាំ ផែនដីស្តេចតាមសោយរាជរៀង ៗ គ្នា ក្នុងនគរគោកធ្លក ទាំងក្នុងផែនដែក បាន ៥ អង្គ ក្នុងរវាង ១៣៣ ឆ្នាំ រួចបានមកព្រះថោង ស្តេចមកពីនគរ ឥន្ទបត្ត ( ហិណ្ឌូ ) ទ្រង់រាជ្យក្នុងពុទ្ធសករាជ ២៧៧ មុនគ្រិស្តសករាជ ២៦៧ ឆ្នាំ តពីស្តេចតាមហើយ តាំងនាមព្រះនគរ «ខេមរៈ» ជាក្រុងកម្ពុជារៀងមកដល់ឆ្នាំម្សាញ់ឯកស័ក ព្រះពុទ្ធសករាជ ២៤៧២ គ្រិស្តសករាជ ១៩២៩ ។ សព្វថ្ងៃនេះ ស្តេចខេមរ សោយរាជ្យត ៗ មកបានប្រមាណ ៧៣ ព្រះអង្គ ( ត្រូវជា ៨២ រាជ្យ ព្រោះព្រះមហាក្សត្រអង្គខ្លះឡើងសោយរាជ្យពីរដង បីដង មួយព្រះអង្គក៏មាន) ក្នុងរវាងប្រមាណ ២១៩៧ ឆ្នាំ ហើយ មិនទាន់បានបោះពុម្ពនៅឡើយ ដោយហេតុថា ត្រូវពិនិត្យឡើងវិញ ឲ្យត្រឹមត្រូវជាមុន ។ តែឥឡូវទ្រង់ព្រះតម្រិះយល់ថា បើនឹងបង្អង់បោះពុម្ពនេះតទៅទៀត នឹងយឺតយូរឥតប្រយោជន៍ ទើបបានទ្រង់សុំឲ្យកុងស៊ីសេនាបតីជំនុំនឹងលោក រ៉េស៊ីដង់ស៊ុបេរីយ៉េរ ឲ្យបោះពុម្ពជាអក្សរខ្មែរ ទុកព្រះរាជពង្សាវតារក្រុងកម្ពុជា តាមសេចក្តីដើម ដែលមានតាំងអស់ ១៣ សៀវភៅជាក្រដាស រិចរិលនៅក្នុងក្រុមព្រះរាជនិពន្ធ ដែលបានរក្សាសព្វថ្ងៃនេះជាប្រញាប់ ទុកសម្រាប់ព្រះនគរ ចែកទៅសាលារៀន និងជាឲ្យអ្នកទាំងពួងបានស្គាល់ព្រះរាជពង្សាវតារ ស្រុករបស់ខ្លួន ។ បើតទៅមុខ គេឃើញសេចក្តីជាក់ច្បាស់ដូចម្តេចនឹងកែប្រែទៅតាមគួរនិងការក៏បាន ។ មួយទៀតទ្រង់គំនិតថា ព្រះរាជពង្សាវតារនេះជាពាក្យកាព្យនិងធ្វើជារឿងល្ខោនរាំផងក៏បាន ។ លុះតែងរួចទ្រង់បានឲ្យបោះពុម្ពជាក្រោយ ។

សេចក្តីនេះ ទ្រង់មានព្រះរាជបុត្រហ្វាយ លេខ ១៥៩ ចុះថ្ងៃសៅរ៍ ៦ កើត ខែអាសុជ ឆ្នាំរោងសំរឹទ្ធិស័ក ព្រះពុទ្ធសករាជ ២៤៧១ ត្រូវនិងថ្ងៃ ២០ ខែ តុលា ឆ្នាំ ១៩២៨ ត្រាស់ដល់កុងស៊ីសេនាបតី ឲ្យប្រឹក្សានឹងលោករ៉េស៊ីដង់ស៊ុបេរីយ៉េរ ពីសេចក្តីសុំបោះពុម្ពនេះ ។ កុងស៊ីសេនាបតីក៏បានជុំនុំ នឹងលោក រ៉េស៊ីដង់ស៊ុបេរីយ៉េរឡេហ្វូល យល់ព្រមតាមសព្វព្រះរាជហឫទ័យ ជាប្រយោជន៍រាស្ត្រផែនដី ដូចមានបុត្រហ្វាយលោកលេខ ២៨០ ចុះថ្ងៃ ១៣ ខែ វិច្ឆិកា ឆ្នាំ ១៩២៨ ត្រូវនិងថ្ងៃអង្គារ ១ កើត ខែ កត្តិក ឆ្នាំរោងសំរឹទ្ធិស័ក ព្រះពុទ្ធសករាជ ២៤៧១ តបមកសេនាបតីក្រសួងសិក្សាធិការស្រាប់ ។

ក្នុងសម័យដែលទ្រង់ត្រាស់បង្គាប់ឲ្យបោះពុម្ព ព្រះរាជពង្សាវតារ ក្រុងកម្ពុជាធិបតី នោះនៅ

គុណវិនេនជ័ព្រះករុណា ដែលមានលោកឡាវិត ជារ៉េស៊ីដង់សុបេរីយើរ ដំណាងក្រុងបារាំងវែសស ក្នុងក្រុងកម្ពុជាធិបតី សម្តេចចៅហ្វាវាំងវរវៀងជ័យអធិបតី ពិភក្តិស្រីង៉ា ឧត្តមក្រុមពាហុ: ជួន សេនាបតីក្រសួងព្រះបរមរាជវាំងព្រះឃ្លាំងមហាសម្បត្តិនិងវេទនា ជាអគ្គសេនាបតី អធិបតីក្រុមជំនុំរាជការ នៃព្រះនគរក្រុងកម្ពុជាធិបតី សម្តេចចក្រីកុញ្ញរាធិបតី ឧត្តមក្រុមពាហុ: ពេជ ប៊ុន សេនាបតីក្រសួងយុទ្ធនាធិកា សង្គ្រាមធិការ និង យោធាធិការ, ក្រុមលួងស៊ីសុវត្ថិ សុគាណាវង្ស ឧត្តមមហាសេនាបតីសិរីអគ្គរក្សសមុហៈនាយក សេនាបតីក្រសួងមហាផ្ទៃនិងធម្មការ អ្នកឧកញ៉ាយមរាជពិភក្តិជាង ឧត្តមក្រុមពាហុ: កូសម្រេចរាជការ ក្រុមព្រះនគរបាល ជាសេនាបតីក្រសួងយុត្តិធម៌, ព្រះអង្គម្ចាស់ននកេត្តមសុកម្រិត ឧក្រឡាហោម ពិភក្តិនាគមហាធិបតី ឧត្តមក្រុមពាហុ: សេនាបតីក្រសួងដែនទឹក ក្សេត្រាធិការ សិប្បយការ និងពាណិជ្ជការ ។

ឧកញ៉ាប្រាជ្ញាធិបតីតាងហ្វាង យិន ក្រុមព្រះរាជនិពន្ធជាអ្នកផ្ទៀង ។

## ឯកសារ មហាបុរសខ្មែរ ចប់តែប៉ុណ្ណោះ

ជាទីបញ្ចប់នេះទូលព្រះបង្គំ ខ្ញុំបាទ សូមប្រសិទ្ធិពរឱ្យសៀវភៅនេះបានជាទីគាប់ចិត្តនៃទ្រង់ លោកអ្នកអាន យ៉ាងក្រៃលែង ព្រោះប្រវត្តិសាស្ត្ររបស់ជាតិនិមួយ ៗ ដែលតែងដោយអ្នកនិពន្ធជាតិរបស់ខ្លួន រមែងតែសម្រួលចិត្ត អ្នកអានឱ្យមានគំនិតជាតិនិយមយ៉ាងមោះមុត ។

សូមគំនាព្រះគុណ, អរគុណ

ហត្ថលេខា **អេង សុត**

ចៅក្រមប្រឹក្សា សាលាវិនិច្ឆ័យ

---

ដំណឹងពិសេស

## រឿងកំពុបតែអុង

ទ្រង់, ឯកឧត្តម អស់លោកដែលមានអាយុលើសពី ៤០ ឆ្នាំឡើងទៅតែងតែបានឮពាក្យថា "កំពុបតែអុង" នេះគ្រប់ ៗ គ្នា ហើយយល់ច្បាស់នូវន័យរបស់ពាក្យនេះទៀតផង ។ ប៉ុន្តែ ពោះប៉ិតអស់លោកដឹងច្បាស់ថា ពាក្យនេះកើតឡើងពីពេលដែលមានមេទ័ពយួនម្នាក់ឈ្មោះ ឡៅ

សូមអានបន្ថែម **ព្រះរាជពង្សាវតារក្រុងកម្ពុជាធិបត**

ជាច្បាប់របស់សម្តេចជហ្វាវាំង **ជួន** ដែល វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យកម្ពុជាទើបយក មកបោះពុម្ពផ្សាយឡើងនាព.ស.២៥៦៥ ត្រូវនឹង គ.ស.២០២១ ដើម្បីរក្សាឯកសារដ៏មាន អត្តប្រយោជន៍សម្រាប់សិស្ស និស្សិតនិងអ្នកស្រាវជ្រាវនានាដែលសិក្សាលើកម្ពុជាដែល ជាចំណែកដ៏ធំមួយសំខាន់នៃប្រវត្តិសាស្ត្រជាតិមានទាំងអស់៥៥០ទំព័រ។

បុព្វបទស្រាវជ្រាវ ដោយ

បណ្ឌិតសភាចារ្យ **ឃីងហុកឌី**



បណ្ឌិតសភាចារ្យ២រូបដែលជាអ្នកឯកទេសព្រះរាជពង្សាវតារប្រទេសកម្ពុជា ដោយលោកបានសិក្សាគ្រប់មុមហើយបានប្រៀបធៀបផ្ទៀងផ្ទាត់ពីឯកសារ១ទៅឯកសារ១ទៀតដោយផ្ទៀងប្រៀធៀបទាំងស្ថានការនិងកាលបរិច្ឆេទ

គឺ៖

១) បណ្ឌិតសភាចារ្យ ឃីនសុខ (១៩៤២ - ២០១១)[3]

២) បណ្ឌិតសភាចារ្យ ម៉ក់ភឺន (នាយកស្រាវជ្រាវនៅមជ្ឈមណ្ឌលជាតិស្រាវជ្រាវវិទ្យាសាស្ត្រក្រុងប៉ារីស ចូលនិវត្តន៍)[4]



(រូបថតកម្មសិទ្ធិ បណ្ឌិតសភាចារ្យ ឃីងហុកឌី,១៩៩៦)

A [3] KHIN Sok, *Chroniques royales du Cambodge (De Banà yat à la prise de Lanvaek) (de 1417 à 1595)*, Traduction française avec comparaison des différentes versions et introduction, Paris, Publ. EFEO, 1988, 471 p.

[4] MAK Phoeun, *Chroniques royales du Cambodge (De 1594 à 1677), Traduction française avec comparaison des différentes versions et introduction, Traduction française avec comparaison des différentes versions et introduction*, Paris, Publ. EFEO, 524 p.

MAK Phoeun, *Chroniques royales du Cambodge (Des origines légendaires jusqu'à Paramaràja), Traduction française avec comparaison des différentes versions et introduction*, Paris, Publ. EFEO, 1984, 465 p.